ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ២នាក់ ពីប្រទេសម៉ាឡេស៊ី**

------------

ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ម៉ាឡេស៊ី** បានរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ ចំនួន**២នាក់** ដូចខាងក្រោម៖

**(១)** ពលករឈ្មោះ **ស.ម** អាយុ៣៦ឆ្នាំ មកពីស្រុកឆ្លូង ខេត្តក្រចេះ បានចាញ់បោកមេខ្យល់ ទៅធ្វើការនៅរោងចក្រអារឈើក្នុងប្រទេសម៉ាឡេស៊ី កាលពីខែមិថុនា ឆ្នាំ២០១៦។ ដោយធ្វើការលំបាក គាត់បានទៅស្ថានទូតនៅថ្ងៃទី២២ ខែវិច្ឆិកា ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានចេញលិខិតធ្វើដំណើរជូន ហើយអង្គការអន្តរជាតិទេសន្តប្រវេសន៍(IOM) ឧបត្ថម្ភសំបុត្រយន្តហោះក្រោមកិច្ចសម្របសម្រួលរបស់ស្ថានទូត។

ពលករ **ស.ម** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២១** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង **១៧:៣០**នាទី តាមជើងយន្តហោះ MH762 ។

**(២)** ពលការិនី **យ.អ** អាយុ២៦ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត ពីខែមករា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូត នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើសុំស្ថានទូត ទាមទារប្រាក់ខែដែលនៅសល់ និងជួយឲ្យបានត្រឡប់មកកម្ពុជា។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ និយោជករបស់ពលការិនី បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ លិខិតឆ្លងដែន និងសំបុត្រយន្តហោះ ដល់នាង។

ពលការិនី **យ.អ** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២២** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជា ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ជូនដល់អ្នកទាំងពីរផងដែរ៕

ភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ